ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

# រយៈពេល ៣ ឆ្នាំ

# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : អូរម៉ាល់

ភូមិ : អូរម៉ាល់

ឃុំ : អំពិលទឹក

ស្រុក : កំពង់ត្រឡាច

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : អូរម៉ាល់

ភូមិ : អូរម៉ាល់

ឃុំ : អំពិលទឹក

ស្រុក : កំពង់ត្រឡាច

ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **អូរម៉ាល់** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី ១០ ខែ **កក្កដា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **អូរម៉ាល់** មានទីតាំងស្ថិតនៅក្នុង ភូមិ **អូរម៉ាល់** ឃុំ **អំពិលទឹក** ស្រុក **កំពង់ត្រឡាច** ខេត្ត **កំពង់ឆ្នាំង** ដែល មានសមាជិកសរុបចំនួន **១៨៦** នាក់ ស្រីចំនួន **៨៦** នាក់ និងមានគណៈកម្មការចំនួន **១១** នាក់ ស្រីចំនួន **២** នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **១៦៣** គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ ចុះធ្វើសកម្មភាពសាមងពោះថ្លាន់ ចុះពិនិត្យព្រៃលិចទឹក និងដាក់បំរាមហាមឃាត់ការកាប់បំផ្លាញព្រៃលិចទឹក បង្ក្រាបបទល្មើសឆក់ត្រីនៅក្នុងសហគមន៍។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក-ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋក្នុងភូមិសរុបក្នុងសហគមន៍នេសាទមាន **៨៥៤** នាក់ប្រុស ៤០០ នាក់ ស្រី **៤៥៤** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន ៨៥៤ នាក់។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ២៩ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៨ នាក់ ស្រី ៧ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៧ នាក់ ស្រី ៩ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន គ្មាន ស្រី គ្មាន
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ៦ នាក់ ស្រី ៤ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%**
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ៦០ នាក់ ស្រី ២៤ នាក់។

### ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើនេសាទចំនួន ៦២ គ្រួសារ
- ធ្វើស្រែចំនួន ៦២ គ្រួសារ ទំហំ ៣៣៦ ហិកតា
- ធ្វើវារីវប្បកម្មចំនួន ១៩ គ្រួសារ ទំហំ ០,៤៥៦ ហិកតា

- ដាំបន្លែចំនួន ៤០ គ្រួសារ
- ជាងផ្ទះចំនួន ៤ គ្រួសារ
- ឈ្មួញកណ្តាល ៤ គ្រួសារ
- ធ្វើចំការចំនួន ៤ គ្រួសារ ទំហំ ១.៥ហិកតា
- លក់ដូរ ចំនួន ៧ គ្រួសារ
- កែច្នៃផលនេសាទ ៦០ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **អូរម៉ាល់** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទ លេខ **២០** ដែននេសាទទឹកសាប ។

កន្លែងនេសាទសហគមន៍ **អូរម៉ាល់** មានទំហំ **២៤៣** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **ភូមិស្ទឹងស្ងួត**
- ខាងត្បូងទល់នឹង **ព្រំប្រទល់ខេត្តកំពង់ចាម**
- ខាងកើតទល់នឹង **ព្រែកកំពង់ចាម**
- ខាងលិចទល់នឹង **ទន្លេ**

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ **អូរម៉ាល់** មានបឹងចំនួន **២** ព្រែកចំនួន **១** ទំនាបចំនួន **១** ស្រះចំនួន **៤៣** និងមេទឹកចំនួន **១** ។

- បឹង **គល់** ទំហំ ៩៥ ហិកតា នេសាទពីខែ ធ្នូ ដល់ខែ មិថុនា
- បឹង **ជំនីក** ទំហំ ៤១ ហិកតា នេសាទពីខែ ធ្នូ ដល់ខែ មិថុនា
- ព្រែក **អាវក្រពើ** ប្រវែង ៨០០ ម៉ែត្រ ទទឹង ០៨ ម៉ែត្រ នេសាទពីខែ សីហា ដល់ខែ ធ្នូ
- ទំនាប **តាក្រូច** ប្រវែង ១០០ ម៉ែត្រ ទទឹង ០៧ ម៉ែត្រ នេសាទពីខែ សីហា ដល់ខែ ធ្នូ
- ស្រះ មានចំនួន **៤៣** ទំហំ ១,៣១២ ហិកតា
- អាងទឹក **ដើមគរគី** ទំហំ ២ ហិកតា
- ដីទំនាបលិចទឹកមានទំហំសរុប **៤៧១** ហិកតា ។

### គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សហគមន៍គ្មានកន្លែងសមស្របដើម្បីធ្វើកន្លែងអភិរក្សទេ ដូចនេះហើយទើប គណៈកម្មការ និងសមាជិកទាំងមូល បានសំរេចចូលជួយការពារតំបន់អភិរក្ស ជាមួយសហគមន៍បឹងកក់ គឺចំនុច **បឹងប្រាំង** ដែលមានទំហំ **៣៧៥០០ម²** (បណ្តោយ២៥០ម ទទឹង ១៥០)។

### ឃ. ធនធានផលផល

- ប្រភេទត្រី :
  - ➢ ប្រភេទត្រីដែលមានការកើនឡើង : កញ្ចុះ ក្រុសខ្នងវែង ក្រុសមេម៉ាយ ច្រកែង
  - ➢ ប្រភេទត្រីដែលមិនថយ និងមិនកើនឡើង : ត្រីរ៉ស ត្រីអណ្តែង ត្រីឆ្លាត ឆ្តោ ត្រីរៀល ត្រីឆ្តោក ក្លាំងហាយ គ្រុំ ក្រឡង់ ចចឡឹង
  - ➢ ប្រភេទត្រីដែលមានការថយចុះ : ត្រីក្រពាត់ សណ្តាយ ស្លឹកឫស្សី កញ្ជនជ័យ ឆ្តិន គល់រាំង កន្ធរក្អែក និងត្រីដីរ។
- ប្រភេទវារីសត្វ : ក្តាម កំពិស ពស់ អន្ទង់ ខ្យង និងខ្ចៅ។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ : រាំង ត្រស់ ទ្រាល ខ្ទាយមាន់ អាញ្ចៀ ថ្នើមអណ្តើក បបួយ អញ្ចាញ បន្លាយូន បន្លាស្អិត ស្វាព្រាម វល្លិធ្មេញត្រី វល្លិប្រេង វល្លិសន្ទៃ វល្លិតាអើក វល្លិសាវម៉ាវព្រៃ ត្រកួន កន្ទាំងហែរ ជីប្លង កំប្លោក ចក។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១៨៦ នាក់ ស្រី ៨៦ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៦៦៨ នាក់ ស្រី ៣៦៨ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៣០ នាក់ ស្រី ១០ នាក់

### ខ. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ:

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ១ដៃ=៥០ម | ២ដៃx៣០នាក់=៦០ | ក្រឡា ២.៥សម<br>ជំរៅ ១,៥ ម<br>ប្រវែង៣០០០ ម | មករា-ធ្នូ |

| | | | | |
|---|---|---|---|---|
| លាន់អន្ទង់ | គ្រឿង | ៥០គ្រឿងx១២ន=៦០០ | ៦០០គ្រឿង | មិថុនា-ធ្នូ |
| សន្ទូចរនង | ផ្លែ | ៥០ផ្លែx២០ន=១០០០ | ១០០០ ផ្លែលេខ១១-១៣ | សីហា-មេសា |
| លបក្លាំងហាយ | គ្រឿង | ៥គ្រឿងx២០ន=១០០ | ចំនួន=១០០ គ្រឿង<br>ក្រឡាត្រៀម=៣សម<br>កំពស់=១.២.មុខកាត់=0.៦ម | មិថុនា-ធ្នូ |
| សំណាញ់ | វង់ | ១០វង់x១០ន=១០០ | ១០ វង់ | មករា-ធ្នូ |
| ទ្រូ | គ្រឿង | ៤គ្រឿងx៧ន=២៨ | ២៨ គ្រឿង | សីហា-កញ្ញា |
| លបត្រីរស់ | គ្រឿង | ៣គ្រឿងx៨ន=២៤ | ចំនួន=២៤គ្រឿង<br>ក្រឡាត្រៀម=៣សម<br>កំពស់=១.២.មុខកាត់=0.៦ម | សីហា-ធ្នូ |
| លបកំពឹស | គ្រឿង | ២៥គ្រឿងx១៥ន=៣៧៥ | ចំនួន=៣៧៥ គ្រឿង | សីហា-ធ្នូ |
| លបត្រីដំរី | គ្រឿង | ៤គ្រឿងx៣ន=១២ | ចំនួន=១២ គ្រឿង<br>ក្រឡាត្រៀម=៣សម<br>កំពស់=១.២.មុខកាត់=0.៦ម | មិថុនា-កញ្ញា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| កាណូត | ១៧២ | ៥០០-១០០០ គក្រ | ៨-១០ សេះ |
| ទូកត្នោត | ៨ | ៧០-១០០ គក្រ | |
| ទូកចែវ | ២០ | ២០០-៥០០គក្រ | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ១ដៃ=៥០ម | ១០០=៥០ x២ដៃ | ប្រវែង៥០០០ ម.ក្រឡា ៣ សម.ជំរៅ ១.៥ ម |
| លបកំពឹស | គ្រឿង | ៣គ្រឿងx៥០នាក់ | ចំនួន=១៥០គ្រឿង |
| សន្ទូចរនង | ផ្លែ | ១០០នាក់ | ២០០០០ ផ្លែ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| កាណូត | ១០០ | ៥០០-១០០០គក្រ | ៨-១០ សេះ |
| ទូកចែវ | ២០ | ២០០-៥០០គក្រ | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ១ដៃ=៥០ម | ៣០=១៥នាក់ x2ដៃ | ក្រឡា ៣ សម. ប្រវែង១៥០០, ជំរៅ ១ ម |
| លាន់អន្ទង់ | គ្រឿង | ៣០គ្រឿងx៥០នាក់ | ១៥០០ គ្រឿង |
| សន្ទូចរនង | ផ្លែ | ៥០ផ្លែx៤០នាក់ | ២០០០ ផ្លែ លេខ១១-១៣ |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក្រ)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៨០០ គក្រ | ៤០០ គក្រ | ១២០០ គក្រ |
| ក្តាម ខ្យង | ១០០ គក្រ | ៥០ គក្រ | ១៥០ គក្រ |
| ល្បែស | ៥០ គក្រ | ២០ គក្រ | ៧០ គក្រ |

# ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **អូរម៉ាល់** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬ កាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវជំនោរឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | |
|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន |
| បឹងគល់ | សីហា-ធ្នូ | មង | ប្រវែង៥០០០មក្រឡា=២.៥-៥សម | ២០០នាក់ |
| បឹងជំនីក | សីហា-ធ្នូ | ទ្រូ | ៥០គ្រឿង | ៥០នាក់ |
| ព្រែកអាវក្រពើ | កក្កដា-វិច្ឆកា | លបត្រីរស់ | ១០គ្រឿង | ១០នាក់ |
| ទំនាបតាក្រូច | សីហា-ធ្នូ | លបត្រីដំរី | ៧៥គ្រឿង | ៧៥នាក់ |
| ទំនាបតាក្រូច | សីហា-ធ្នូ | លបកំពឹស | ១០០០គ្រឿង | ១០០០គ្រឿង |

### គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងជំនីក | ៤១ហិកតា | ប=១០០មទ=៥០ម<br>ជំរៅ=១.៥ម | -ប្រជុំផ្សព្វផ្សាយ<br>-ចុះពិនិត្យទីកន្លែង<br>-ជួលគ្រឿងចក្រ ឬឱ្យអង្គពលកម្ម | ៦/៤/២០០៩ | ៦/៤/២០១០ | |

### គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងប្រាង | ប=២៥០មទ=១៥០ម | ត្រីមេពូជ | ប្រជុំផ្សព្វផ្សាយ បោះបង្គោល ដាក់ស្លាកសញ្ញា រុំខ្សែលួស ល្បាត | ៥/៣/២០០៩ | ៥/១០/២០១០ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក | ៣ ហិកតា | ច្រកែង,រាំង | ផ្សាំ,បណ្តុះ | ២០០៩ | ២០១០ | ៤០០ដុល្លា |
| ២-ថែរក្សា និង រំលោះព្រៃលិចទឹក | | ថែរក្សា | ថែរក្សា | ថែរក្សា | ថែរក្សា | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ៨ | អណ្តែង | ៣២០ គក្រ | ធ្នូ ២០០៩ | មិនា ២០១០ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូល សរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ផ្សព្វផ្សាយពីការដាក់ពាក្យសុំចូលជាសមាជិក ទទួលពាក្យសុំ និងប្រមូលប្រាក់បង់សមាជិកភាព | ២/៤/២០០៩ | ២/៤/ ២០១០ | ១០០០៛x១៨៦ន= ១៨៦ ០០០៛ | |
| ភាគទានប្រចាំឆ្នាំ | ផ្សព្វផ្សាយពីផលប្រយោជន៍ភាគទានប្រចាំឆ្នាំ និងប្រមូលភាគទាន | ២/៥/២០០៩ | ២/៥/ ២០១០ | =១៨៦ ០០០៛ | |

| | | | | | |
|---|---|---|---|---|---|
| | ប្រចាំឆ្នាំ | | | | |
| ជំនួយសប្បុរសជន និងអង្គការនានា | រៀបចំធ្វើផែនការជាមួយក្រុមប្រឹក្សាឃុំ ដើម្បីអភិវឌ្ឍន៍សហគមន៍ | ២/១/២០០៩ | ២/៥/២០១០ | ៥០០ដុល្លារ | |

## គ-៧ ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាពសហគមន៍

| ប្រភេទមុខរបរ | សកម្មភាព និងចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ចិញ្ចឹម ត្រី,ជ្រូក, មាន់ | មាន់ ៣ក្បាល/គ្រួសារ (១០គ្រួសារ)<br>ជ្រូក២ក្បាល/គ្រួសារ (១០គ្រួសារ) | ២/៥/២០០៩ | ២/5/២០១០ |
| ដាំបន្លែ (ននោង, សណ្តែកគួ, ស្ពៃខៀវ, ស្ពៃចង្កឹះ) | ២០ គ្រួសារ | ៤/៣/២០០៩ | ១/៣/២០១០ |
| បណ្តុះផ្សិត | ១គ្រួសារ/២រង (១០គ្រួសារ) | ១/៣/២០០៩ | ១/៣/២០១០ |

## គ-៨ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ៦ បង្គោល | តាមចំណុចដែលបានកំនត់ក្នុងផែនទីសហគមន៍ | គណៈកម្មការសហគមន៍នេសាទ | កុម្ភៈ ២០០៩ | មិនា ២០១១ | ត្រូវការជំនួយនិងការសហការណ៏ពី ស្ថាប័នជំនាញ និងអង្គការនានា |

## គ-៩ ផែនការផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹង

| ប្រធានបទ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| លក្ខន្តិកៈនិង បទបញ្ជាផ្ទៃក្នុងសហគមន៏នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៣ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| សារៈប្រយោជន៏នៃធនធានធម្មជាតិ និងបរិស្ថាន | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| ផែនទីកំណត់ព្រំប្រទល់កន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៨ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| ផែនការគ្រប់គ្រងកន្លែងនេសាទ | សមាជិក និង | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |

| | | | |
|---|---|---|---|
| | គណៈកម្មការស.ន | | |
| ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងដល់ការគ្រប់គ្រងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៩ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| ការគ្រប់គ្រង និងសារៈប្រយោជន៍នៃព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ២ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |

## គ-១០ ផែនការពង្រឹងសមត្ថភាពសហគមន៍

| ផែនការ | ប្រធានបទ/ជំនាញ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ពង្រឹងស្ថាប័ន និង ការងារគ្រប់គ្រង | ការធ្វើកំណត់ហេតុ និង របាយការណ៍ | គណៈកម្មការស.ន | កុម្ភៈ ២០០៩ | រដ្ឋបាលជលផល CFC |
| | របៀបសរសេរខិតរដ្ឋបាល | គណៈកម្មការស.ន | កក្កដា ២០០៩ | រដ្ឋបាលជលផល CFC |
| | រៀបចំទុកដាក់ឯកសារសហគមន៍ និងរបៀបកត់ត្រាប្រចាំថ្ងៃ | គណៈកម្មការស.ន | មិថុនា ២០០៩ | រដ្ឋបាលជលផល CFC |
| | ការគ្រប់គ្រងថវិកា | គណៈកម្មការស.ន | កុម្ភៈ ២០០៩ | រដ្ឋបាលជលផល CFC |
| | ការដោះស្រាយទំនាស់ | គណៈកម្មការស.ន | | រដ្ឋបាលជលផល CFC |
| | ការទំនាក់ទំនង និង សរសេរសំណើសុំថវិកា | គណៈកម្មការស.ន | មេសា ២០០៩ | រដ្ឋបាលជលផល CFC |
| | រៀបចំបណ្តាញសហគមន៍ | គណៈកម្មការស.ន | សីហា ២០០៩ | រដ្ឋបាលជលផល CFC |
| | ទស្សនៈកិច្ចសិក្សារផ្លាស់ប្តូរបទពិសោធន៍ | គណៈកម្មការស.ន | ១ដង/ឆ្នាំ | រដ្ឋបាលជលផល CFC |
| បណ្តុះបណ្តាលបច្ចេកទេស | បណ្តុះ និងដាំព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | កញ្ញា ២០០៩ | រដ្ឋបាលជលផល CFC |
| | ចិញ្ចឹមត្រី និងសត្វ | សមាជិក និង គណៈកម្មការស.ន | កុម្ភៈ ២០០៩ | រដ្ឋបាលជលផល CFC |
| | បណ្តុះផ្សិត | សមាជិក និង គណៈកម្មការស.ន | មិនា ២០០៩ | រដ្ឋបាលជលផល CFC |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែល ទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរក ថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួល បានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ អូរម៉ាល់ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | - ផ្សព្វផ្សាយផែនការប្រើប្រាស់ឧបករណ៍នេសាទដល់សមាជិកសហគមន៍ទាំងអស់និងអ្នកមកពីខាងក្រៅ<br>-ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំ | - សមាជិក និងអ្នកមិនមែនជាសមាជិកសហគមន៍ទាំងអស់បានជ្រួតជ្រាបពីផែនការ<br>- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ នាំឱ្យត្រីមានការកើនឡើង | - ចំណាយលើការផ្សព្វផ្សាយ ១៥០ ដុល្លា<br>- ចំណាយលើការចុះល្បាត ត្រួតពិនិត្យតាមដាន ២០០ ដុល្លា | - ជំនួយអង្គការនិងសប្បុរសជននានា<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៩-២០១០ | ២០០៩-២០១០ | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | ផ្សព្វផ្សាយដល់សមាជិក | ព្រៃក្នុងសហគមន៍កើនឡើង | ៥០០ | អង្គការនានាស្ថាប័នជំនាញ | ២០០៩-២០១០ | | |
| ៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែង ៨ស្រះ ១០ម × ១០ម ចំនួន ៣២០ គក្រ | -ជីវភាពប្រជាជនកើនឡើង<br>-បង្កើនជីវភាពគ្រួសារ | ១០០ ដុល្លា | - សប្បុរសជន<br>- អង្គការ និង ជំនាញ | ធ្នូ ២០០៩-២០១០ | មិនា ២០០៩ | |
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | - ប្រមូលប្រាក់សមាជិកភាព និង ភាគទានប្រចាំឆ្នាំ<br>- ស្វែងរកជំនួយបន្ថែមពីអង្គការ និងសប្បុរសជននានា | សមាជិកស.នទាំងអស់នឹងបង់ប្រាក់តាមការកំនត់ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>- អង្គការ និងសប្បុរសជននានា | - គ្មានការចំណាយ | - | ២០០៩ | ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | និងជួយគាំទ្រតាមរយៈការផ្តល់សំភារៈ និងថវិកាដល់ស.ន | | | | | |
| ៧- ផែនការបង្កើនមុខរបរ ទ្រទ្រង់ជីវភាព | វិភាគនិងចាត់អាទិភាពជំរើសមុខរបរចិញ្ចឹមជីវិត ស្វែងរកអង្គការ ស្ថាប័នគាំទ្រ – រៀបចំសំណើសុំថវិកា | – ជំរើសមុខរបរចិញ្ចឹមជីវិតត្រូវបានកំនត់ និងចាត់អាទិភាព សំណើសុំថវិកាត្រូវបានរៀបចំ និងទទួលបានការគាំទ្រពីអង្គការនានា | – ចំណាយសរុប ៥០០០ $ | – ជំនួយអង្គការ និងសប្បុរសជននានា – ថវិកាអភិវឌ្ឍន៍ឃុំ – ប្រាក់បដិភាគរបស់សហគមន៍ | ២០០៩-២០១០ | ២០១០ | |
| ៨- ផែនការបោះបង្គោល ព្រំប្រទល់សហគមន៍ | សហការជាមួយជំនាញផែនទីកំនត់ទីតាំងត្រូវបោះបង្គោល – ស្វែងរកថវិកាគាំទ្រ | បង្គោលត្រូវបានបោះត្រឹមត្រូវតាមចំនុចដែលកំនត់លើផែនទី ស.នមានព្រំប្រទល់ច្បាស់លាស់កាត់បន្ថយជម្លោះ | – ចំណាយសរុប ៣០០ ដុល្លា | – ជំនួយអង្គការ និងសប្បុរសជននានា – ថវិកាអភិវឌ្ឍន៍ឃុំ – ប្រាក់បដិភាគរបស់សហគមន៍ | កុម្ភៈ ២០០៩-២០១១ | មិនា ២០០៨ | |
| ៩- ផែនការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង | – ផ្សព្វផ្សាយឱ្យស.គបានលស់ដឹងពី លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនិងស.ន | – ស.គបានយល់ដឹង និងអនុវត្តតាម | – ១០០ ដុល្លា | – ជំនួយអង្គការ និងសប្បុរសជននានា – ថវិកាអភិវឌ្ឍន៍ឃុំ – ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០១០ | ធ្នូ ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០- ផែនការពង្រឹងសមត្ថភាពសហគមន៍ | - បង្កើនសមត្ថភាពស.គទាំងជំនាញ គ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | ស.គចេះជំនាញផ្សេងៗទាក់ទិន និងការងារគ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ១០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៩ | ធ្នូ ២០០៨ | |
| ១១-ផែនការកែលំអដែននេសាទ | ប=១០០មទ=៥០ម ជំរៅ=១.៥ម | -ប្រជុំផ្សព្វផ្សាយ<br>-ចុះពិនិត្យទីកន្លែង<br>-ជួលគ្រឿងចក្រ ឬឱ្យអង្គពលកម្ម | ៨០០០ដុល្លារ | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៩-២០១០ | | |
| ១២-ផែនការអភិរក្ស | ត្រីមេពូជ ប=២៥០មទ=១៥០ម | -ប្រជុំផ្សព្វផ្សាយ<br>-ចុះពិនិត្យទីកន្លែង<br>-រុំខ្សែលួស បោះបង្គោល ល្បាត | ១០០០ដុល្លារ | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៩-២០១០ | | |

តារាងកម្មវិធីការងារ

| សកម្មភាព | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់ស.គ | | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | |

បានឃើញ និងបញ្ជូនមក

លោកនាយ...រដ្ឋបាលជលផល

**នាយសង្កាត់រដ្ឋបាលជលផល**.....

.........ថ្ងៃទី...10...ខែ...9.........ឆ្នាំ ២០០8

លេខ :.................

បានឃើញ

**មេឃុំ**..........

..............ថ្ងៃទី...10...ខែ...9.........ឆ្នាំ ២០០8

លេខ :...385.......

.......ថ្ងៃទី...9...ខែ...9.........ឆ្នាំ ២០០8

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ :...02.........

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

...........ថ្ងៃទី...27...ខែ...11.........ឆ្នាំ ២០០8

**នាយអធិការដ្ឋាន រដ្ឋបាលជលផល**.....

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋាន រដ្ឋបាលជលផល.....

............ថ្ងៃទី...21...ខែ...10...ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល**.....